**Program:**

**Topic:** Burke and Hare

(បុរសពីរនាក់ដែលសហការគ្នាធ្វើជាឃាតករ និងគាស់ផ្នូរយកសាកសពទៅលក់)

**Categories:** Crime Investigation

**Publish Date:**

**Content by:** Prey Reung



---

សូមស្វាគមន៍មកកាន់ CamID Podcast

កាលពីសវទី១៨ គឺធ្លាប់មានព្រឹត្តិការមួយ ដែលមនុស្សពីរនាក់ សហការគ្នាធ្វើជាឃាតករសម្លាប់មនុស្ស ដើម្បីយកគេពិសោធន៍។

រឿងរ៉ាវនេះគឺជារឿងរ៉ាវឃាតកម្មដ៏ចម្លែកមួយ ដែលឃាតក គឺមានគ្នាដល់តែ២ នាក់ឯណោះ។ ហើយមានសំណួរជាច្រើនដែលសួរនៅជុំវិញរឿងរ៉ាវឃាតកម្មនេះ ថាតើហេតុបានជាគេទាំងពីរធ្វើបែបនេះ? ហើយចុងក្រោយ តើជីវិតរបស់ឃាតកទាំង២ទៅជាយ៉ាងណា? ហើយរឿងរ៉ាវនេះបានកើតឡើងយ៉ាងដូចម្តេច?

ដើម្បីស្រាយចម្ងល់ យើងទៅតាមដានទាំងអស់គ្នា។

នៅក្នុងចន្លោះឆ្នាំ១៨២៧-១៨២៨ មានករណីឃាតកម្ម ដែលគួរអោយភ្ញាក់ផ្អើលមួយកើតឡើងនៅប្រទេស Scotland។ នាពេលនោះ គឺជាពេលមួយ ដែលអ្នកវិទ្យាសាស្រ្ត កំពុងតែសិក្សាយ៉ាងសស្រាក់សស្រាំ ទៅលើកាយវិភាគសាស្រ្តរបស់មនុស្ស។

អ្នកទាំងអស់គ្នាប្រាកដជាស្គាល់ហើយថា កាយវិភាគសាស្រ្តគឺជាអ្វី ពោលគឺគ្រានោះ សាលាពេទ្យមួយនៃប្រទេស Scotland ត្រូវការសាកសពមនុស្សជាច្រើន ដើម្បីយកមកវះកាត់ផ្តាច់ចេញពីគ្នាទៅតាមផ្នែកនីមួយៗ នៃអាវយវរបស់មនុស្ស រួចហើយយកមកសិក្សា ក៏ប៉ុន្តែតាមច្បាប់ អ្នកវិទ្យាសាស្រ្ត អាចមានសិទ្ធយកតែសាកសពណា ដែលក្រុមគ្រួសារគេស្ម័គ្រចិត្តបរិច្ចាកអោយ ឬអ្នកទោសដែលត្រូវគេកាត់ទោសប្រហារជីវិតតែប៉ុណ្ណោះ។

ឃាតកម្មដែលស្លាប់មនុស្សអស់យ៉ាងហោចណាស់១៥នាក់ ដោយសារតែបុរសពីរនាក់នេះគឺ ផ្តើមចេញពីមនុស្សម្នាក់ ដែលស្លាប់ទៅហើយ តែនៅជាប់ជំពាក់លុយបុរស ២ នាក់នេះ។

ចង់ដឹងថាឃាតករពីរនាក់នេះជាអ្នកណា ហើយហេតុអ្វីបានជាពួកគេ មិនលើកលែងអោយ សម្បីតែអ្នកដែលជំពាក់លុយពួកគេស្លាប់ទៅហើយក៏ដោយ?

ថ្ងៃនេះ ព្រៃរឿងនឹងលើកយកឃាតកម្មមួយ ដែលទាក់ទងនឹងប្រវត្តិ នៃមុខវិទ្យាកាយវិភាគសាស្រ្ត មកបកស្រាយ។

ដំណើររឿង ប្រព្រឹត្តទៅក្នុងទិដ្ឋភាពមួយ នៅប្រទេស Scotland ដែលគ្រានោះ មានសាលាសិក្សាកាយវិភាគសាស្ត្រមួយ ដែលមានសិស្ស និសិត្សជាច្រើន ត្រូវការសាកសពមនុស្សយកមកពិសោធន៍ ដើម្បីសិក្សាពីរាងកាយមនុស្ស។

ដោយសារតែតម្រូវការច្រើន ទើបនាំអោយមានហេតុការណ៍មួយកើតឡើងនៅទីក្រុង Edinburgh នៃប្រទេស Scotland

ហេតុការណ៏នេះ គឺជាករណីបាត់ផ្នូរខ្មោចនោះឯង។ ជារឿងធម្មតាទៅហើយ ដែលសាច់ញាតិនៃសព ត្រូវតែចាំយាមើលផ្នូររបស់អ្នកដែលស្លាប់ទៅ។ ជាពិសេសសាកសពដែលទើបតែស្លាប់ កាន់តែស្រស់គឺ កាន់តែបានលុយច្រើន។ ហេតុការណ៍នេះបានជាករណីបាត់ផ្នូរខ្មោចផ្ទុះឡើងនៅរវាងចន្លោះឆ្នាំ ១៨២៧-១៨២៨។

រឿងរ៉ាវនេះ បានធ្វើអោយបុរសពីរនាក់ ក្លាយជាឃាតក សម្លាប់មនុស្សយ៉ាងអន្ទះសារ ព្រោះតែសេចក្ដីលោភលន់នឹងទឹកប្រាក់។

បុរសពីរនាក់នេះគឺ William Burke និង William Hare។ Burke និងHare មានស្រុកកំណើតតែមួយ មកពីខេត្ត Ulster ភាគខាងជើងនៃប្រទេស Ireland

ក្រោយមកពួកគេក៏បានចំណាក់ស្រុក មកនៅប្រទេស Scotland វិញ  ដើម្បីធ្វើការចិញ្ចឹមក្រពះ។ Burke មិនបានយកប្រពន្ធ និងកូនរបស់គាត់ពីរនាក់មកតាមនោះទេ ពោលគឺ Burke បានបោះបង់គ្រួសាររបស់គេ នៅឯប្រទេស Ireland ហើយមករស់នៅតំបន់កំពង់ផែខាងលិច ក្នុងទីក្រុង Edinburgh នៃប្រទេស Scotland ជាមួយស្រីកំណាញ់របស់គាត់ ឈ្មោះHelen McDougal យ៉ាងរំភើយ។

បើនិយាយពី Hare វិញ គាត់រស់នៅលើផ្លូវតែមួយជាមួយ Burke ដែរ ។ Hare រស់នៅជាមួយស្ត្រីមេម៉ាយម្នាក់ ឈ្មោះថា Margaret Laird។ Magaret ត្រូវគេស្គាល់ជាប្រពន្ធរបស់

Hare បើទោះបីជាពួកគេ មិនទាន់រៀបការស្របច្បាប់ក៏ដោយ។ ម្យ៉ាងទៀតពួកគេទាំងពីរ គឺជាម្ចាស់ផ្ទះជួល នៅទីនោះផងដែរ។

ក្រោយមក Burke និងHare ជួបគ្នារួច ក៏ក្លាយទៅជាមិត្តភិក្ដិចិត្តជិត តាំងពីពេលហ្នឹងមក។

សំណួរសួរថា បន្ទាប់ពីបានស្គាល់គ្នា តើមិត្តភាពរបស់ពួកគេនឹងទៅជាយ៉ាងណា?

មិត្តភាពរបស់ពួកគេ មិនបានដូចអ្វីដែលប្រជាជន Scotland រំពឹងនោះទេ ផ្ទុយទៅវិញ នៅខែធ្នូ ឆ្នាំ១៨២៧ បុរសចំណាស់ម្នាក់ឈ្មោះថា Donald ដែលជាអ្នកជួលផ្ទះរបស់ Hare បានស្លាប់ដោយតែជម្ងឺចាស់ជរា ក៏ប៉ុន្តែ Donald នៅជាប់បំណុលថ្លៃផ្ទះជួលចំនួន£4.00។

ដើម្បីជាថ្នូរនៃការដោះបំណុល Hare និងBurke ក៏បានលួចទៅគាស់ផ្នូរតា Donald រួចក៏យកសាកសពរបស់គាត់ ទៅលក់អោយសាលាពេទ្យ នៅសាកលវិទ្យាល័យមួយនៃទីក្រុង Edinburg។

នៅទីនោះ មានសាស្ត្រាចារ្យផ្នែកកាយវិភាគសាស្ត្រម្នាក់ ឈ្មោះថា Robert Knox ចាំទទួលស្វាគមន៍ Burke និងHare និងសាកសពតា Donald ក្នុងតម្លៃ £7.10។

ដោយសារតែទឹកប្រាក់ សាកសពមានតម្លៃថ្លៃជាងបណ្ណុលរបស់ពួកគេ វាក៏បានធ្វើអោយ Burke និងHare កើតចិត្តចង់ក្លាយជាឃាតក ចាប់ពីពេលនោះមក។

លុះនៅឆ្នាំ១៨២៨ ពួកគេក៏ធ្វើសកម្មភាពម្តងទៀត តែលើកនេះ គឺពួកគេញៀននឹងសម្លាប់មនុស្សតែម្តង ពោលគឺនៅពេលដែល អ្នកជួលផ្ទះរបស់ Hare ម្នាក់ទៀត ឈ្មោះថា Joseph ធ្លាក់ខ្លួនឈឺ។

ដោយមិនចង់ឃើញ Joseph ស្លាប់ដោយសារតែជម្ងឺរបស់គេទៅដោយការឈឺចាប់ និងស្របពេលដែលមានចិត្តអន្ទះអន្ទែង ចង់អោយ Joseph ស្លាប់លឿនផងនោះ Burke និង Hare ក៏បានធ្វើពុត ជាអ្នកកំដរ ដោយបង្ខំអោយ Joseph ផឹកស្រាវិស្គីអោយស្រវឹងរួច Burke និងHare ក៏យកដៃខ្ទប់មាត់ និងច្រមុះ Joseph រហូតដល់ Joseph ដាច់ខ្យល់ស្លាប់។

គួរបញ្ជាក់ផងដែរថា ការសម្លាប់បែបនេះ បាយក្លាយទៅជាវិធីពិសេសមួយរបស់Burke និងHare ព្រោះវិធីនេះ គឺមិនបន្សល់ស្លាក់ស្នាមរបួសនៅលើរាងកាយនោះទេ ហើយម្យ៉ាងទៀត ក៏សិស្សនិសិត្សដែលយកទៅវះកាត់នោះ ក៏មិនដឹងថា សាកសពនេះត្រូវគេសម្លាប់ដែរ ដោយសារតែសាកសពមានជម្ងឺស្រាប់ទៅហើយ។

ក្រោយមក ដោយវត្តមានអ្នកដែលជួលផ្ទះរបស់ Hare មិនមានអ្នកណាឈឺ Burke និងHare ក៏សម្រេចចិត្តធ្វើជាចិត្តល្អ ទៅលួងជនរងគ្រោះអោយទៅស្នាក់អាស្រ័យនៅផ្ទះរបស់ពួកគេ រួចក៏សម្លាប់ជនរងគ្រោះទាំងនោះតែម្តង។ អ្នកដែលស្លាប់នោះ ភាគច្រើនគឺមកពីសហគមន៏ដែលក្រីក្រ ហើយមិនសូវមានអ្នកណាស្គាល់នោះទេ។

ចាប់តាំងពីពេលនោះមក ចេះតែមាន អ្នកភូមិ អ្នកស្រុក តែងតែបាត់សាច់ញាតិ ជាបន្តបន្ទាប់ជានិច្ច រហូតដល់មានពាក្យចរចាមរាមថា ក្មេងៗដែលបាត់ខ្លួន ត្រូវបានគេចាប់យកទៅវះកាត់ពិសោធន៍ ដោយសារតែគេចាប់ជំរិត និងសម្លាប់ ក៏ប៉ុន្តែ វិជ្ជបណ្ឌិតជាច្រើននៅជំនាន់នោះ ក៏បានបដិសេធ និងរុញច្រានរឿងនេះ ហើយក៏មានអ្នកខ្លះជឿរឿងនេះដែរ ដែលធ្វើឲ្យរឿងនេះ ល្បីល្បាញ និង កើតឡើងនៅទីក្រុង Edinburgh នោះឯង។

មកដល់ចំណុចនេះ ព្រៃរឿងសូមបញ្ជាក់ផងដែរថា គ្រានោះ Burke និងHare សម្លាប់មនុស្សយ៉ាងហោចណាស់១៥ នាក់ ដែលក្នុងនោះ រួមមានស្ត្រី១២នាក់ ជនពិការដែលជាយុវវ័យ ២នាក់ និងមនុស្សចាស់ម្នាក់។

ពួកគេទាំងពីរសម្លាប់មនុស្សអស់ជាច្រើនទៀត ក៏ប៉ុន្តែ តាមការសិក្សារបស់ព្រៃរឿង មិនមានប្រភពណាមួយ បញ្ជាក់ពីចំនួនពិតប្រាកដនៃអ្នកស្លាប់នោះទេ។

រឿងរ៉ាវមិនទាន់ចប់ត្រឹមនេះនោះទេ តួយ៉ាង មានស្ត្រីម្នាក់ដែលជានារីរកស៊ីផ្លូវភេទ ឈ្មោះថា Janet Brown។ Janet ជាស្ត្រីតែមួយគត់ ដែលមានសំណាងរួចផុតពីសេចក្តីស្លាប់ ដែលគ្រានោះ Janet និងមិត្តភិក្តរបស់នាងម្នាក់ទៀតឈ្មោះថា Mary Patterson ត្រូវបាន Burke និងHare

អញ្ជើញទៅផ្ទះរបស់ពួកគេពេលល្ងាច តែ Janet បានបដិសេធ។ ដោយទីបំផុត Janet មិនដឹងថា Mary ដែលជាមិត្តរបស់នាង ត្រូវBurke និងHare សម្លាប់នោះឡើយ ហើយខ្លួននាងផ្ទាល់បិះនឹងក្លាយជាជនរងគ្រោះបន្ទាប់ទៅហើយ។

ជាងនេះទៅទៀតBurke និងHare កាន់តែលោភលន់ និងកាន់តែសាហាវឃោរឃៅថែមទៀតផង ដែលក្រោយមក ពួកគេបានសម្លាប់យាយចាស់ម្នាក់ ដោយបង្ខំអោយគាត់ លេបថ្នាំបំបាត់ការឈឺចាប់ជាច្រើនគ្រាប់ រហូតដល់ស្លាប់

មិនតែប៉ុណ្ណោះ ថែមទាំងសម្លាប់ចៅប្រុសរបស់គាត់ ដែលពិការភ្នែកថែមទៀតផង។ Burke និងHare បានកាច់បំបាក់ឆ្អឹងខ្នង របស់ចៅប្រុសរបស់គាត់ រហូតដល់ចង្កុង។

វាស្តាប់ទៅ Burke និងHare ដូចត្រូវវិញ្ញាណបីសាចសណ្ឋិតចូលអីចឹង ព្រោះពួកគេ សម្លាប់មនុស្សគ្មានមេត្តានោះទេ។

អ្នកទាំងអស់គ្នា ប្រកដជាឆ្ងល់ហើយថា តើស្រីកំណាញ់របស់ Burke មិនដឹង ឬក៏យ៉ាងណា? តាមការពិត ស្រីកំណាញ់របស់ Burke គឺHelenមិនត្រឹមតែដឹងនោះទេ ថែមទាំងសាច់ញាតិរបស់នាងឈ្មោះថា Ann ជួយជញ្ជូនសាកសពយកទៅលក់ផងដែរ។

មិនយូរប៉ុន្មាន សិស្សមួយចំនួនរបស់វិជ្ជបណ្ឌិត Knox បានចំណាំមុខ Mary ដែលត្រូវបានសម្លាប់នោះ និងស្ត្រីពេស្យាពីរនាក់ទៀត ដែលត្រូវឃាតករមួយគូរនេះ បានសម្លាប់គឺ Elizabeth Halden និងកូនស្រីរបស់នាង។ ដំបូងឡើយ ឃាតកនោះគឺសម្លាប់តែម្ដាយប៉ុណ្ណោះ តែដោយសារពេលនោះ កូនរបស់នាងបានដើរ រកម្ដាយរបស់នាងនៅកន្លែងBurke និងHare ដែលធ្វើឲ្យឃាតកនោះសម្លាប់ទាំងកូនស្រីរបស់នាងទៀត។

មិនយូរនោះឡើយ Burke និងHare ក៏មានជម្លោះជាមួយគ្នា គឺដោយសារតែ Burke ធ្វើអោយគេសង្ស័យ ក្រោយមកគ្រួសាររបស់ Hare ក៏បានចែកផ្លូវគ្នារៀងខ្លួនជាមួយគ្រួសាររបស់ Burke។

ជម្លោះនេះគឺដោយសារតែ នៅថ្ងៃបុណ្យ Halloween ឆ្នាំ១៨២៨ ជនរងគ្រោះចុងក្រោយរបស់ពួកគេឈ្មោះថា Majory ដែលត្រូវ Burke អញ្ជើញមកស្នាក់នៅផ្ទះរបស់គេ ស្របពេលដែលអ្នកដែលត្រូវ Burke អញ្ជើញ ២នាក់ទៀតគឺ James និងAnn Gray អោយមកស្នាក់នៅផ្ទះរបស់ Hare សិន។

នៅថ្ងៃបន្ទាប់ Gray និងJames បានទៅផ្ទះរបស់ Burke។ ចៃដន្យGrayក៏បានឃើញសាកសពរបស់ Majory នៅក្រោមគ្រែរបស់ Burke និង Helen។

រឿងនេះក៏បានបែកធ្លាយ ហើយពួកគេទាំងពីរបានសន្យាថាអោយសំណូក Gray £10 ក្នុងមួយអាទិត្យ ក៏ប៉ុន្តែ Gray មិនព្រមនោះទេ Grayក៏បានទៅផ្តឹងប៉ូលិស។ ប៉ុន្តែមុនពេលប៉ូលិសមកដល់ Burke និង Hare បានយកសាកសព Majory ទៅលក់អោយលោកគ្រូពេទ្យ Knox បាត់ហើយ។

ទីបំផុតBurke និងHare ត្រូវបានប៉ូលិស Ireland ចាប់ខ្លួន រួចពួកគេក៏ចោទគ្នាទៅវិញទៅមក។ ការស៊ើបអង្កេត និងការកាត់ទោសក៏បានដាប់ផ្តើម។ ប៉ូលិសក៏បានទៅជួបលោកវិជ្ជបណ្ឌិត Knox រីឯ James និងGray ក៏បានបង្ហាញអត្តសញ្ញាណ Majory ទៅកាន់ប៉ូលិស ដែលសាកសព Majory កំពុងតែស្ថិតនៅបន្ទប់វះកាត់។

ចំណែកឯ Janet ដែលជានារីរកស៊ីផ្លូវភេទដ៏សំណាងម្នាក់នោះ ក៏បានយកអាវរបស់ជនរងគ្រោះដទៃដែលរកឃើញនៅផ្ទះរបស់ Hare អោយទៅប៉ូលិស។

ការកាត់ទោស ធ្វើឡើងនៅអំឡុងពេល Christmas ឆ្នាំ១៨២៨ ដែល Burke និងHelen បានជាប់ទោសពីបទឃាតកម្មសម្លាប់មនុស្ស។ ក្រោយមក Helen ដែលជាប្រពន្ធ Burke ក៏បានតុលាការដោះលែងអោយមានសេរីភាព ដែលការផ្សំគំនិតរបស់នាងត្រូវបានច្បាប់របស់ប្រទេស Scotland ជាអ្នកសម្រេច។

ជាចុងក្រោយនៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៨២៩ Burke ត្រូវបានកាត់ទោសប្រហារជីវិតដោយចងកជាសារធារណៈ នៅនឹងមុខប្រជាជន Scotland ២៥០០០នាក់ ហើយសាកសពរបស់ Burke

ត្រូវបានសិស្សនិសិត្សផ្នែកកាយវិភាគសាស្ត្រយកមកសិក្សា និងស្បែករបស់Burke ធ្វើជាសៀវភៅថែមទៀតផង រីឯគ្រោងឆ្អឹងរបស់គេ ក៏ត្រូវបានគេដាក់តាំងក្នុងបន្ទប់វះកាត់ដែរ។

ចំណែកឯ Hare ក៏ត្រូវបានតុលាការកាត់ទោសពីបទផ្សំគំនិតដែរក៏ប៉ុន្តែ Hare បានរត់គេចទៅប្រទេសអង់គ្លេស តាំងពីអំឡុងពេលស៊ើបអង្កេតមកម្លេះ។ មានពាក្យចាចាមរាមខ្លះថា Hareក្លាយជាអ្នកពិការភ្នែកសំទានបាត់ហើយ។ គួរបញ្ជាក់ផងដែរថា Helen បានភៀសខ្លួនទៅកាន់ប្រទេស Australia ហើយ Magaret បានត្រឡប់ទៅកាន់ប្រទេស Ireland វិញ។

បើក្រឡេកទៅមើលវិជ្ជបណ្ឌិត Knox វិញ គឺគាត់មិនបានជាប់ទោសអ្វីឡើយ ព្រោះ Burke បានប្រាប់តុលាការថា គេមិនដឹងថាសាកសពនោះមកពីណានោះទេ។ កេរ្តិ៍ឈ្មោះរបស់ Knox ក៏បានធ្លាក់ចុះ រួចក៏ទៅរស់នៅ London និងប្រកបរបរជាអ្នកលក់ថ្នាំពេទ្យវិញ។

តាមរយៈរឿងរ៉ាវនេះ យើងអាចស្វែងយល់បានថា ដើម្បីលុយ មនុស្សខ្លះសុខចិត្តបំផ្លាញអ្នកដទៃ នឹងប្រព្រឹត្តអំពើដែលខុសយ៉ាងធ្ងន់ធ្ងរពីមនុស្សជាតិ។ មិនត្រឹមតែប៉ុណ្ណោះ ការរាប់អានមនុស្សជុំវិញខ្លួនគឺពិតជាសំខាន់ណាស់ មនុស្សមួយចំនួន ធ្វើឲ្យយើងដើរទៅផ្លូវអាក្រក់ ហើយមនុស្សមួយចំនួនក៏នាំមកនូវភាពរីកចម្រើនចំពោះខ្លួន អ្នកជុំវិញ និងសង្គមផងដែរ។

យើងនឹងជួបគ្នាម្តងទៀត ជាមួយ CamID Podcast ក្រោយ។

សម្រាប់ពេលនេះ សុបិនល្អ និងរាត្រីសួស្តី។

Links and resources

https://www.historic-uk.com/

https://www.ed.ac.uk/

https://www.edinburghlive.co.uk/

https://www.britannica.com/

https://www.encyclopedia.com/